# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤.សសរ

# សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មការចាត់ចែងការធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាមេរិក របស់ជនជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- ពិនិត្យសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

### <u>សំរេច</u>

<u>ប្រការ១</u>: ត្រូវបានបង្កើតគណៈកម្មការចាត់ចែងការធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាមេរិក របស់ជនជាតិកម្ពុជា ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| - លោកឧត្តមសេនីយ៍ត្រី **មៀច សុផាន់ណា** | ប្រធាននាយកដ្ឋានគ្រប់គ្រងជនបរទេស | ប្រធាន |
| - លោកឧត្តមសេនីយ៍ត្រី **ម្នួក សារឿន** | ប្រធានលេខាធិការដ្ឋានក្រុមអ្នកច្បាប់ | សមាជិក |
| - លោក **ស៊ីន ស៊ីវុត្ថា** | ប្រធាននាយកដ្ឋានព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ | សមាជិក |
| - លោក **កែវ ទិសិទ្ធ** | អនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

<u>ប្រការ២</u>: គណៈកម្មការនេះមានភារកិច្ច :

- ចូលរួមជាមួយមន្ត្រីបច្ចេកទេសនៃសហរដ្ឋអាមេរិក ដើម្បីប្រជុំពិភាក្សា និងរៀបរៀងខ្លឹមសារ

" **អនុស្សារណៈនៃការយោគយល់គ្នា** " រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា និងនាយកដ្ឋានសញ្ជាតូបនីយកម្មនិងអន្តោប្រវេសន៍ នៃរដ្ឋាភិបាលសហរដ្ឋអាមេរិក ស្តីពីការធ្វើមាតុភូមិនិវត្តន៍ពីសហរដ្ឋអាមេរិករបស់ជនជាតិកម្ពុជា ដោយឈរលើមូលដ្ឋានគោរពអធិបតេយ្យភាព មានផលប្រយោជន៍ទៅវិញទៅមក គោរពសិទ្ធិមនុស្ស និងស្របតាមច្បាប់នៃប្រទេសទាំងពីរកម្ពុជា-អាមេរិក ។

- ពិនិត្យ ស្រាវជ្រាវ និងចងក្រងសំណុំឯកសារផ្សេងៗពាក់ព័ន្ធនឹងការស្នើសុំធ្វើមាតុភូមិនិវត្តន៍ តាមករណីនីមួយៗរបស់បុគ្គលម្នាក់ៗ ដាក់ជូនអាជ្ញាធរកណ្តាលពិនិត្យ និងសំរេច ។

<u>ប្រការ៣</u> : គណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយត្រូវរាយការណ៍លទ្ធផលការងាររបស់ខ្លួនជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

<u>ប្រការ៤</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកឧត្តម អស់លោក ដូចមានក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅភ្នំពេញ,ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០០២*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**ចំលងជូន**</u> :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចក្នុងប្រការ១ និងប្រការ៤
-ឯកសារ-កាលប្បវត្តិ